Declassified to Public
12 June 2020

លេខ / No: D27/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

លេខសំណុំរឿង: ០០៤/០៧-០៩-២០០៩/អ.វ.ត.ក./ក.ស.ច.ស.

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ចំពោះមុខ ៖ **ចៅក្រម យូ ប៊ុនឡេង**

**ចៅក្រម Siegfried BLUNK**

កាលបរិច្ឆេទ ៖ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១

ភាសា ៖ អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

# ដីកាសម្រេចស្ដីអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 17 / 06 / 2011
ម៉ោង (Time/Heure) : 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

00707440

០០៤/០៧-០៩-២០០៩/អ.វ.ត.ក./ក.ស.ច.ស. លេខ/No: D27/1

យើង Siegfried BLUNK (**ស៊ីគហ្វ្រីដ ប៊្លុង**) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញវិធាន ២១ វិធាន ៥៥ និង វិធាន ៧១ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក (វិសោធនកម្មលើកទី ៧) ("វិធានផ្ទៃក្នុង")

បានឃើញលិខិតផ្ទេរសិទ្ធិដែលធ្វើឡើងដោយលោកចៅក្រម យូ ប៊ុនឡេង ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១

បានឃើញថា នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ក្នុងគោលបំណងដើម្បីបំពេញបន្ថែម និងបំភ្លឺអំពីអង្គហេតុដែលត្រូវស៊ើបសួរដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៤ ក៏ដូចជាដើម្បីបន្ថែមទីតាំងឧក្រិដ្ឋកម្មថ្មីៗនៅក្នុងតំបន់១នៃភូមិភាគពាយ័ព្យ និងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តលើប្រជាជនខ្មែរក្រោមនៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ។

បានឃើញថា សំណើសុំនេះត្រូវបានដាក់ក្នុងនាមសហព្រះរាជអាជ្ញាអន្តរជាតិជាលក្ខណៈបុគ្គល និងមានចម្លងជូនសហព្រះរាជអាជ្ញាជាតិ។ សហព្រះរាជអាជ្ញាអន្តរជាតិ បានជូនដំណឹងផងដែរថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះត្រូវបានដាក់ស្របតាមវិធាន ៧១(៣) ហើយការខ្វែងយោបល់គ្នាលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះត្រូវបានកត់ត្រាចូលក្នុងកំណត់ហេតុ និងត្រូវបានយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នា ដែលរក្សាទុកដោយក្រឡាបញ្ជីនៃការិយាល័យសហព្រះរាជអាជ្ញា ដោយអនុលោមតាមវិធាន ៧១(១) នៃវិធានផ្ទៃក្នុង[1]។

[1] D27 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ២១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ២២ ។

00707441

០០៤/០៧-០៩-២០០៩/អ.វ.ត.ក./ក.ស.ច.ស. លេខ/No: D27/1

ដោយហេតុថា ដោយអនុលោមតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង នៅក្នុងដំណើរការស៊ើបសួរ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកប ដោយតម្លាភាព សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវស្វែងរកការពិតទាក់ទងនឹងពេលវេលាដែលកំណត់ ហេតុនៃការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបានធ្វើឡើង ដោយស្របទៅនឹងបញ្ញត្តិនៃវិធាន ៧១(១) នៃវិធានផ្ទៃក្នុង ។

**អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតសម្រេច៖**

**បង្គាប់** សហព្រះរាជអាជ្ញាឲ្យធ្វើការបង្ហាញក្នុងរយៈពេល០២ថ្ងៃនៃថ្ងៃធ្វើការ អំពីពេលវេលាដែលកំណត់ ហេតុនៃការខ្វែងយោបល់ត្រូវបានធ្វើឡើង ដោយអនុលោមតាមបញ្ញត្តិនៃវិធាន ៧១(១) នៃវិធានផ្ទៃក្នុង ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១

**សហចៅក្រមស៊ើបអង្កេត**